00343902

C22/5/37

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

*តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី*
*ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម*
*ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០២/១៩-០៩-២០០៧/អវតក/កសចស (អបជ១៧)

**ចំពោះមុខ:** ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន៉ីយ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**ក្រឡាបញ្ជី:** សរ ចំនួរ៉ាត
Entela JOSIFI

**កាលបរិច្ឆេទ:** ២៦ ខែមិថុនា ឆ្នាំ២០០៩

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 26 / 06 / 2009
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A. Fuy

---

សាធារណៈ (សំណៅកោសលុប)

## សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេច របស់សហចៅក្រមស៊ើបអង្កេត អំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន

---

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 26 / 06 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A. Fuy

**ការិយាល័យសហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT
យ៉ែត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

**ជនត្រូវចោទ**
អៀង សារី

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

| | |
|---|---|
| ហុង គឹមសួន | Silke STUDZINSKY |
| ឡោ ជុនធី | Martine JACQUIN |
| នី ចាន់ឌី | Philippe CANONNE |
| គង់ ពិសី | Pierre Olivier SUR |
| យុង ផានិត | Elizabeth RABESANDRATANA |
| គីម ម៉េងឃី | Olivier BAHOUGNE |
| ម៉ុច សុវណ្ណារី | David BLACKMAN |
| | Annie DELAHAIE |

**សហមេធាវីការពារក្តី**
អាង ឧត្តម
Michael G. KARNAVAS

00343903



**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "អ.វ.ត.ក" បានទទួល "បណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត អំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នលោក អៀង សារី" ដែលបានដាក់នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៨ ("បណ្តឹងឧទ្ធរណ៍")។

## I. សេចក្តីផ្តើម

១. អង្គបុរេជំនុំជម្រះបានយោងរំលឹកឡើងវិញ និងអនុម័តរបាយការណ៍ស្តីពីការត្រួតពិនិត្យសំណុំរឿងចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីដំណើរការនីតិវិធី និងអង្គហេតុនិងអង្គច្បាប់ទាក់ទងនឹងបញ្ហានេះ ដែលរបាយការណ៍នេះត្រូវបានភ្ជាប់ជាមួយសាលដីកានេះ[1]។

២. នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ អង្គបុរេជំនុំជម្រះ បានចេញដីកាកំណត់កាលបរិច្ឆេទសវនាការ ដែលសវនាការត្រូវកំណត់ធ្វើនៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩[2]។

៣. មុនពេលសវនាការ អង្គបុរេជំនុំជម្រះបានទទួលសិទ្ធិត្រួតពិនិត្យសំណុំរឿង ដែលត្រូវបានធ្វើបច្ចុប្បន្នភាព។ ក្នុងគោលបំណងពិចារណាបណ្តឹងឧទ្ធរណ៍នេះ អង្គបុរេជំនុំជម្រះបានពិនិត្យឡើងវិញនូវឯកសារនានានៅក្នុងសំណុំរឿង និងភស្តុតាងទាំងអស់រហូតដល់ត្រឹមថ្ងៃទី២ ខែមេសា ឆ្នាំ២០០៩ ដែលជាកាលបរិច្ឆេទចុងក្រោយនៃសវនាការបណ្តឹងឧទ្ធរណ៍នេះ។

៤. នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ អង្គបុរេជំនុំជម្រះបានស្តាប់បញ្ហាបឋមនានារបស់សហមេធាវីការពារក្តី[3]។ អង្គបុរេជំនុំជម្រះសម្រេចពន្យារពេលសវនាការរហូតដល់ថ្ងៃទី២ ខែមេសា ឆ្នាំ

---

[1] របាយការណ៍ស្តីពីការត្រួតពិនិត្យសំណុំរឿង អ.ប.ជ១៧, ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៩, C22/5/17។

[2] ដីកាកំណត់កាលបរិច្ឆេទសវនាការ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩, C22/5/10។

[3] សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរនៃសេចក្តីសម្រេចដោយផ្ទាល់មាត់ក្នុងការស្តាប់សក្ខីកម្មវេជ្ជបណ្ឌិត Falke, ពន្យារពេលសវនាការដោយសារស្ថានភាពសុខភាពរបស់ជនត្រូវចោទ និងបន្តសវនាការដើម្បីឲ្យសហមេធាវីការពារក្តីរបស់ជនត្រូវចោទ ធ្វើសេចក្តីសន្និដ្ឋានថា ហេតុអ្វីបញ្ហាសុខភាពមានភាពចាំបាច់សម្រាប់អង្គបុរេជំនុំជម្រះពិចារណា, ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៩, C22/5/24។

២០០៩។ នៅថ្ងៃទី២ ខែមេសា ឆ្នាំ២០០៩ អង្គបុរេជំនុំជម្រះបានស្តាប់សេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់ភាគី នានា។

## II. ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

៥. នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ អៀង សារី "ដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួន"។ នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៨ សហមេធាវីការពារក្តីបានទទួលសេចក្តីជូនដំណឹងអំពីការបន្តថិរវេលានៃការឃុំខ្លួន និងបានដាក់បណ្តឹងឧទ្ធរណ៍។ សារណាបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៨ និងធ្វើឡើងទៅតាមពេលវេលាកំណត់ដែលមានចែងនៅក្នុងវិធាន ៧៥(៣) នៃវិធានផ្ទៃក្នុងអ.វ.ត.ក ("វិធានផ្ទៃក្នុង")។

## III. ច្បាប់ជាធរមាន

៦. វិធាន៦៣ នៃវិធានផ្ទៃក្នុងបានចែងទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្នថា:

"២. ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នត្រូវតាក់តែងឡើងដូចខាងក្រោម:

ក- បញ្ជាក់អំពីអង្គហេតុ និងអង្គច្បាប់ដែលនាំឱ្យមានការឃុំខ្លួន ដោយផ្អែកទៅលើអនុវិធាន ៣ ខាងក្រោម។

[...]

៣. សហចៅក្រមស៊ើបអង្កេត អាចចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ បានតែក្នុង លក្ខខណ្ឌដូចខាងក្រោម:

ក- មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្ត បទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។

ខ- សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការដ៏ចាំបាច់ដើម្បី:

(១) រារាំងកុំឲ្យជនដែលត្រូវចោទនោះគាបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ ឬ រារាំងកុំឲ្យមានការត្រូវរូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិតចំពោះបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ។

(២) ថែរក្សាភស្តុតាង ឬការពារមិនឲ្យបំផ្លាញភស្តុតាង។

(៣) ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី។

(៤) ការពារសន្តិសុខឲ្យជនដែលត្រូវចោទ ឬ

(៥) រក្សាសណ្តាប់ធ្នាប់សាធារណៈ។

[...]

៦. ការឃុំខ្លួនបណ្តោះអាសន្នអាចធ្វើឡើងដូចខាងក្រោម៖

ក- ចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី១ (មួយ) ឆ្នាំបានទេ។ ប៉ុន្តែសហចៅក្រម ស៊ើបអង្កេតអាចពន្យារពេលការឃុំខ្លួនបណ្តោះអាសន្នបន្ថែមម្តងបាន១ (មួយ) ឆ្នាំ។

[...]

៧. ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវមានសំអាងហេតុចំពោះការពន្យារពេលនៃការបន្តឃុំខ្លួនបណ្តោះអាសន្ន។ ការពន្យារពេលនៃការឃុំខ្លួនបណ្តោះ អាសន្នអាចធ្វើបានតែក្នុងករណី ដែលសហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ជនត្រូវចោទនិងមេធាវីរបស់ជនត្រូវចោទ ហើយត្រូវផ្តល់រយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ ដើម្បីទុកពេលឲ្យប្តឹងតវ៉ាទៅសហចៅក្រមស៊ើបអង្កេត។ ទោះជាយ៉ាងណាក៏ដោយ ការពន្យារពេលមិនត្រូវឲ្យលើសពី ២ (ពីរ) ដងបានឡើយ។ ដីកាសម្រេចនេះបើកផ្លូវប្តឹងឧទ្ធរណ៍"។

## IV. លក្ខណៈនៃបណ្តឹងឧទ្ធរណ៍

៧. នៅក្នុងបណ្តឹងឧទ្ធរណ៍ សហមេធាវីការពារក្តីស្នើសុំអង្គបុរេជំនុំជម្រះឲ្យ៖

ក. "ទុកជាមោឃៈ នូវដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នដែលបានចេញនៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨ និងបង្គាប់ឲ្យមានការដោះលែងលោក អៀង សារី ជាបណ្តោះអាសន្ន។ ឬ

ខ. បង្គាប់ឲ្យ ក.ស.ច.ស កែប្រែលក្ខខណ្ឌនៃការឃុំខ្លួនស្របតាមវិធាន៦៣(៨) និងអនុញ្ញាតឲ្យមានលក្ខខណ្ឌឃុំខ្លួននៅក្នុងផ្ទះ ដូចដែលបានពិពណ៌នាខាងលើ”[4]។

សហមេធាវីការពារក្តីបានលើកអំណះអំណាងថា សហចៅក្រមស៊ើបអង្កេតមិនបានដឹកនាំការស៊ើបអង្កេតដោយយកចិត្តទុកដាក់ និងមិនបានគោរពសិទ្ធិមនុស្សជាសារវន្តរបស់ជនត្រូវ-ចោទ”[5]។

៨. នៅក្នុងចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាបានស្នើសុំអង្គបុរេជំនុំជម្រះបដិសេធចោលបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើមូលដ្ឋានដែលថា ជនត្រូវចោទ “បានខកខានមិនបានបង្ហាញឲ្យឃើញថា មានការផ្លាស់ប្តូរជាក់ស្តែងណាមួយអំពីកាលៈទេសៈនោះទេ តាំងតែពីរូបគាត់ ត្រូវបានសហចៅក្រមស៊ើបអង្កេតសម្រេចឃុំខ្លួនពីដំបូងនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២00៧ មក”[6]។

៩. នៅក្នុងចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ ដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំអង្គបុរេជំនុំជម្រះ បដិសេធចោលបណ្តឹងឧទ្ធរណ៍ ដោយសារតែ“ដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនរបស់[ក.ស.ច.ស] គឺសមហេតុផល និងមានយុត្តិកម្ម ហើយការប្រើប្រាស់ឆន្ទានុសិទ្ធិត្រូវបានធ្វើឡើងយ៉ាងត្រឹមត្រូវ”[7]។

---

[4] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៥៣។

[5] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១។

[6] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ស្តីពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន “ចម្លើយតបរបស់សហព្រះរាជអាជ្ញា” ថ្ងៃទី៩ ខែមករា ឆ្នាំ២00៩, C22/5/7 កថាខណ្ឌ២។

[7] សេចក្តីសន្និដ្ឋានរួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចបន្តឃុំខ្លួនបណ្តោះអាសន្ន (“សេចក្តីសន្និដ្ឋានរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី”) ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២00៨, C22/5/6 កថាខណ្ឌ៣៥។

00343907



១០. បើតាមការសម្រេចរបស់ខ្លួនទាក់ទងនឹងបញ្ហានៃការឃុំខ្លួន[8] និងសារណានានារបស់ភាគី ដូចមានចែងនៅក្នុងរបាយការណ៍ស្ដីពីការត្រួតពិនិត្យសំណុំរឿង អង្គបុរេជំនុំជម្រះនឹងពិនិត្យឡើងវិញនូវដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្ដីពីការបន្តចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន តាមរយៈការពិនិត្យមើលចំណុចដូចខាងក្រោម៖

ក. មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

ខ. មូលហេតុដែលបង្ហាញថា ការឃុំខ្លួនគឺជាវិធានការចាំបាច់។

គ. ការយកចិត្តទុកដាក់ក្នុងការដឹកនាំដំណើរការកិច្ចស៊ើបសួរ។

ឃ. សំណើរបស់សហមេធាវីការពារក្ដីជនត្រូវចោទ ស្នើសុំឱ្យដោះលែង ឬកែប្រែលក្ខខណ្ឌនៃការឃុំខ្លួនដោយការអនុញ្ញាតឱ្យមានលក្ខខណ្ឌឃុំខ្លួននៅក្នុងផ្ទះវិញ។

## V. **ការពិចារណា**

**ក. មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជនត្រូវចោទធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (វិធាន ៦៣(៣)(ក))**

១១. នៅក្នុងដីកាបន្តចិរវេលានៃការឃុំខ្លួន សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ឃើញថា ទាំងដីកាសម្រេចនៃការឃុំខ្លួនបណ្ដោះអាសន្ន និងសាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្ដោះអាសន្នបានរកឃើញថា សំណុំរឿង "មានភស្តុតាង ដែលអាចធ្វើឱ្យអ្នកសង្កេត-

[8] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទ នួន ជា ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន របស់សហចៅក្រមស៊ើបអង្កេត ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩, C9/4/7 និងសាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទ អៀង ធីរិទ្ធិ ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩, C80/5/18។

00343908



ការណ៍ដោយមិនលំអៀងជឿថា នៅត្រឹមដំណាក់កាលនៃការស៊ើបអង្កេតនេះ ជនត្រូវចោទធ្លាប់បានប្រព្រឹត្តបទល្មើសដែលខ្លួនត្រូវបានចោទប្រកាន់"[9]។

១២. សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់បន្ថែមទៀតថា៖

> "ចាប់តាំងពីថ្ងៃសវនាការនៃបណ្តឹងឧទ្ធរណ៍នោះមក សហចៅក្រមស៊ើបអង្កេតនៅតែបន្តកិច្ចស៊ើបសួររបស់ខ្លួន ចំពោះបទចោទប្រកាន់ ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររហូតមក។ ប៉ុន្តែនៅក្នុងសំណុំរឿង មិនទាន់មានភស្តុតាងថ្មីណា ដែលផ្ទុយទៅនឹងភស្តុតាងដែលអង្គបុរេជំនុំជម្រះយកមកធ្វើជាមូលដ្ឋាននៃសេចក្តីសម្រេចរបស់ខ្លួននៅឡើយទេ ជាហេតុធ្វើឲ្យសំអាងហេតុរបស់អង្គបុរេជំនុំជម្រះនៅតែមានសុពលភាព [...]"[10]។

១៣. សហចៅក្រមស៊ើបអង្កេតបានប្រកាន់ជំហរថា ដោយសារតែចរិតលក្ខណៈថ្មីៗនៃការពិចារណារបស់អង្គបុរេជំនុំជម្រះលើសំណុំរឿង សហចៅក្រមស៊ើបអង្កេតមិនយល់ឃើញថា មានការចាំបាច់ក្នុងការបកស្រាយបន្ថែមលើភស្តុតាងសំខាន់ៗនោះទេ ហេតុដូច្នេះសហចៅក្រមស៊ើបអង្កេតបានគាំទ្រលើការពិចារណារបស់អង្គបុរេជំនុំជម្រះថា ជាសេចក្តីសង្ខេបត្រឹមត្រូវក្នុងករណីរឿងក្តី អៀង សារី។

១៤. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា៖

> "ដោយសារហេតុផលទាំងនេះ និងបន្ទាប់ពីបានពិនិត្យលើភស្តុតាង ដែលមាននៅក្នុងសំណុំរឿងទាំងអស់ សហចៅក្រមស៊ើបអង្កេតធ្វើសេចក្តីសន្និដ្ឋានថា នៅត្រឹមដំណាក់កាលនៃកិច្ចស៊ើបសួរនេះ ភស្តុតាងដែលប្រមូលបានទាំងអស់ អាចនឹងធ្វើឲ្យអ្នកសង្កេតការមិនលម្អៀងជឿបានថា អៀង សារី ក្នុងនាមជារដ្ឋមន្ត្រីក្រសួងការបរទេស បាន៖

[9] ដីកាសម្រេចបន្តឋិរវេលានៃការឃុំខ្លួន កថាខណ្ឌ១១ និង១២។

[10] ដីកាសម្រេចបន្តឋិរវេលានៃការឃុំខ្លួន កថាខណ្ឌ១៣។

ក) ប្រើប្រាស់អំណាច និងការគ្រប់គ្រងលើក្រសួងការបរទេស និងស្ថាប័ននៅក្រោមចំណុះ។

ខ) ក្នុងនាមជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា បានជម្រុញ បញ្ជា ខកខានក្នុងការបង្ការ់ និងផ្តន្ទាទោសឬជួយនិងលើកទឹកចិត្តដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលខ្លួនត្រូវបានចោទប្រកាន់"[11]។

១៥. សហមេធាវីការពារក្តីបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួនថា សហចៅក្រមស៊ើបអង្កេតមិនបានបង្ហាញអំពីភស្តុតាងថ្មីដែលប្រមូលបាននោះទេ ចាប់តាំងពីពេលអង្គបុរេជំនុំជម្រះ ធ្វើការពិចារណាលើភស្តុតាងជាលើកចុងក្រោយ[12]។ សហមេធាវីការពារក្តីបានតវ៉ាថា៖

"ដូចនេះ ក.ស.ច.ស គឺគ្រាន់តែវិលត្រឡប់ទៅប្រើប្រាស់ភស្តុតាង ដែលអង្គបុរេជំនុំជម្រះបានយកជាសំអាងរួចមកហើយ នៅក្នុងសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួនរបស់ខ្លួន។ ទោះបីជាភស្តុតាងនេះអាចត្រូវបានពិចារណាថាមានលក្ខណៈគ្រប់គ្រាន់ នៅពេលដែលដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្នដើមត្រូវបានចេញក្នុងខែវិច្ឆិកា ឆ្នាំ២០០៧ ក៏ដោយ ការបង្ហាញភស្តុតាងច្បាស់លាស់ជាងនេះគឺជាការចាំបាច់ បន្ទាប់ពីការឃុំខ្លួនអស់រយៈពេលមួយឆ្នាំកន្លងមក ក្នុងអំឡុងពេលនៃការស៊ើបសួរ។ ដោយខកខានមិនបានកំណត់ភស្តុតាងថ្មីណាមួយទាក់ទងនឹងថាតើ លោក អៀង សារី អាចបានប្រព្រឹត្តឧក្រិដ្ឋកម្មដែលខ្លួនកំពុងត្រូវបានចោទ ដើម្បីបំពេញបន្ថែមទៅលើភស្តុតាង ដែលបានកំណត់រួចហើយដោយអង្គបុរេជំនុំជម្រះនោះ ក.ស.ច.ស មិនបានបំពេញភារកិច្ចរកភស្តុតាងដាក់បន្ទុក ដើម្បីបង្ហាញថាលក្ខខណ្ឌនៃវិធាន៦៣(៣)(ក) ត្រូវបានបំពេញនោះទេ"[13]។

១៦. នៅក្នុងចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា "ភាគីប្តឹងឧទ្ធរណ៍ មិនជំទាស់ទៅនឹងការកំណត់លើមូលហេតុដែលត្រូវបានរកឃើញយ៉ាងច្បាស់នៃ

---

[11] ដីកាសម្រេចបន្តចិរវេលានៃការឃុំខ្លួន កថាខណ្ឌ១៦។

[12] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ២១។

[13] ដីកាសម្រេចបន្តចិរវេលានៃការឃុំខ្លួន កថាខណ្ឌ២២។

00343910



សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួននោះទេ។ គាត់គ្រាន់តែជំទាស់ទៅនឹងកង្វះខាតក្នុងការយកចិត្តទុកដាក់ហួតចត់របស់សហចៅក្រមស៊ើបអង្កេតតែប៉ុណ្ណោះ នៅក្នុងកិច្ចដំណើរការស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេត [...]"[14]។ សហព្រះរាជអាជ្ញា បានរៀបរាប់អំពីការផ្តល់ភស្តុតាងបន្ថែមដែលមាននៅក្នុងសំណុំរឿងនាខែថ្មីៗនេះ ដែលមានកាន់តែច្រើនឡើងទាំងចំនួន និងភាពធ្ងន់ធ្ងរ[15]។ សហព្រះរាជអាជ្ញាបានបន្ថែមថា "មិនមានភស្តុតាងដោះបន្ទុកសំខាន់ៗ ត្រូវបានរកឃើញដើម្បីធ្វើឱ្យអន្តរាយដល់ការកំណត់បាននូវ "អត្ថិភាពនៃមូលហេតុដែលត្រូវបានរកឃើញយ៉ាងច្បាស់" នេះទេ"[16]។

១៧. នៅក្នុងចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា៖

> "ក.ស.ច.ស បានដាក់សេចក្តីសំអាងហេតុចំនួនប្រាំពីរទំព័រ ដែលបានបញ្ជាក់សេចក្តីសម្រេចរបស់ ខ្លួនក្នុងការពន្យារការឃុំខ្លួននេះ។ ទាក់ទងនឹងវិធានផ្ទៃក្នុង ៦៣(៣)(ក) [ក.ស.ច.ស] បានយោងជាសំខាន់ទៅលើសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដែលបានចេញផ្សាយសេចក្តីសម្រេចរបស់ខ្លួននាពេលថ្មីៗនេះ។ [ក.ស.ច.ស] បានបន្ថែមភស្តុតាងថ្មីផ្សេងទៀតបន្ទាប់ពីសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ"[17]។

១៨. អង្គបុរេជំនុំជម្រះបានសង្កេតឃើញថា នៅក្នុងបណ្តឹងឧទ្ធរណ៍ សហមេធាវីការពារក្តីជនត្រូវ-ចោទមិនបានតវ៉ាអំពីអត្ថិភាពនៃមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថាជនត្រូវចោទ អាចមានការទទួលខុសត្រូវចំពោះបទល្មើសនានាក្រោមការស៊ើបអង្កេត

---

[14] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ២២។

[15] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ២៣ និង២៤។

[16] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ២៦។

[17] សេចក្តីសន្និដ្ឋានរួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចបន្តឃុំខ្លួនបណ្តោះអាសន្ន ("សេចក្តីសន្និដ្ឋានរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី") ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៨, កថាខណ្ឌ២៥។

ហេតុដូច្នេះ អង្គបុរេជំនុំជម្រះនឹងមិនពិនិត្យភស្តុតាងដែលមាននៅក្នុងសំណុំរឿង មុនពេលបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់នោះទេ។

១៩. សហមេធាវីការពារក្តីបានតវ៉ាថា ទោះបីជាមានអត្ថិភាពនៃភស្តុតាងដែលបង្កើតឱ្យមានមូលហេតុ ដែលត្រូវបានរកឃើញនៅពេលចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន "កម្រិតនៃភស្តុតាងបន្ថែមត្រូវតម្រូវឱ្យមាន ដើម្បីបំពេញលក្ខខណ្ឌនៃវិធាន៦៣(៣)(ក) បន្ទាប់ពីលោក អៀង សារី បានស្ថិតក្រោមការឃុំខ្លួនអស់រយៈពេលមួយឆ្នាំ"។

២០. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា នៅក្នុងដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួន សហចៅក្រមស៊ើបអង្កេតបានលើកឡើងថា សហចៅក្រមស៊ើបអង្កេត បានពិនិត្យមើលភស្តុតាងដែលមាននៅក្នុងសំណុំរឿងទាំងអស់ និងដោយសារតែការពិចារណារបស់អង្គបុរេជំនុំជម្រះ នាពេលថ្មីៗទៅលើសំណុំរឿង សហចៅក្រមស៊ើបអង្កេត មិនចាត់ទុកថា វាជាចាំបាច់ក្នុងការពិចារណាលើភស្តុតាងសំខាន់ៗដែលបង្ហាញអំពីអត្ថិភាពនៃ "មូលហេតុដែលត្រូវបានរកឃើញយ៉ាងច្បាស់" នោះទេ។

២១. អង្គបុរេជំនុំជម្រះសង្កេតឃើញថា នៅពេលដែលមានការជឿជាក់យ៉ាងច្បាស់លាស់ថា មានអត្ថិភាពនៃ "មូលហេតុដែលត្រូវបានរកឃើញយ៉ាងច្បាស់" រួចហើយ លក្ខខណ្ឌនៃវិធាន៦៣(៣)(ក) នៅក្នុងដំណាក់កាលនៃដំណើរការនីតិវិធីមុនពេលជំនុំជម្រះ នៅតែត្រូវបានបំពេញ លើកលែងតែមានភស្តុតាងដោះបន្ទុកត្រូវបានរកឃើញផ្សេងពីនេះទៅវិញ។ ប៉ុន្តែនៅពេលដែលមានកម្រិតនៃការសង្ស័យ ឬចម្ងល់ដែលកើតមាននៅដំណាក់កាលបន្តបន្ទាប់ទៀតនៃដំណើរការនីតិវិធីព្រហ្មទណ្ឌ កម្រិតនៃការសង្ស័យ ដែលចាំបាច់ដើម្បីជំទាស់យុត្តិកម្មនៃការឃុំខ្លួនមុនពេលជំនុំជម្រះក្តី គឺមានតែក្នុងករណីដែលថា ការសង្ស័យឬចម្ងល់ ត្រូវបានគេចាត់ទុក "សមហេតុផល" និងភស្តុតាងដែលដាក់នៅក្នុងសំណុំរឿង បានបង្ហាញការសង្ស័យ ឬចម្ងល់ពិតជាសមហេតុផល។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេត បានអនុវត្តឆន្ទានុសិទ្ធិយ៉ាងត្រឹមត្រូវក្នុងការសន្និដ្ឋានថា ពិតជាមាន "មូលហេតុដែលត្រូវបានរកឃើញយ៉ាងច្បាស់" ប្រាកដមែន។

២២. ដោយសារតែមានការតវ៉ារបស់សហមេធាវីការពារក្តី ទាក់ទងនឹងការចោទប្រកាន់អំពីកង្វះខាតនៃការយកចិត្តទុកដាក់ក្នុងការស៊ើបអង្កេត អង្គបុរេជំនុំជម្រះនឹងពិចារណាលើបញ្ហានេះនៅក្នុងកថាខណ្ឌ ជាបន្តបន្ទាប់ដូចខាងក្រោម[18]។

២៣. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ចម្លើយសាក្សីថ្មីៗ និងឯកសារនានា ដែលបានដាក់បញ្ចូលនៅក្នុងសំណុំរឿង បានបន្ថែមលើភស្តុតាងទាំងអស់ដែលមាន ដែលគាំទ្រលើមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជនត្រូវចោទអាចធ្លាប់បានប្រព្រឹត្តបទល្មើសជាច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[19]។

២៤. ក្រោយពីបានពិនិត្យមើលសំណុំរឿង*សាឡើងវិញជាថ្មី* អង្គបុរេជំនុំជម្រះមិនបានរកឃើញភស្តុតាងដោះបន្ទុកនោះទេ។ សហមេធាវីការពារក្តីជនត្រូវចោទមិនបានផ្តល់នូវភស្តុតាងដោះបន្ទុកនៅក្នុងបណ្តឹងឧទ្ធរណ៍នោះទេ។ ស្ថិតក្រោមកាលៈទេសៈទាំងនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា មិនត្រឹមតែមាន "មូលហេតុដែលត្រូវបានរកឃើញយ៉ាងច្បាស់" ដែលអាចធ្វើឱ្យអ្នកសង្កេតការណ៍ដោយមិនលំអៀងជឿថា ជនត្រូវចោទអាចធ្លាប់ទទួលខុសត្រូវ ឬបានប្រព្រឹត្តបទល្មើសជាច្រើន ដែលបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដូចដែលមានចែងនៅក្នុងដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនរបស់សហចៅក្រមស៊ើបអង្កេតតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានការបង្ហាញឱ្យឃើញថាមានភស្តុតាងបន្ថែមកាន់តែច្រើនឡើងនៅពេលបច្ចុប្បន្ននេះទៀតផង។

## ខ. ថាតើនៅតែមាន ឬមិនមានមូលដ្ឋានគ្រប់គ្រាន់ ដែលថាការឃុំខ្លួនគឺជាវិធានការចាំបាច់ (វិធានថ្មីក្នុង៦៣(៣)(ខ))

---

[18] សូមមើលកថាខណ្ឌ៣៨-៤៦ ខាងក្រោម។

[19] សូមមើលចម្លើយសាក្សីឈ្មោះ [កោសលុបចោល] ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៩, D141/1។ ចម្លើយសាក្សីឈ្មោះ [កោសលុបចោល] ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៩, D144 និង D147។ ឯកសារចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៩, D155.3 [កោសលុបចោល] ទំព័រ២៧០ និង២៧៥។

00343913



២៥. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ក្រៅតែពីអាយុច្រើន និងអង្គហេតុដែលថាប្រពន្ធរបស់គាត់ ក៏ស្ថិតនៅក្នុងការឃុំឃាំង សហមេធាវីការពារក្តីជនត្រូវចោទមិនបានបង្ហាញអំពីអង្គហេតុ ឬកាលៈទេសៈថ្មី ដែលបង្ហាញថា លក្ខខណ្ឌដែលមានចែងនៅក្នុងវិធាន៦៣(៣)(ខ) មានការផ្លាស់ប្តូរ ដើម្បីធ្វើឱ្យសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះនេះជឿថា មិនចាំបាច់មានការឃុំខ្លួន នាពេលបច្ចុប្បន្ននេះទេ។

២៦. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា នៅក្នុងដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួន សហចៅក្រមស៊ើបអង្កេតបានផ្តល់នូវមូលហេតុគ្រប់គ្រាន់ក្នុងការរកឃើញថា ហានិយភ័យដែលជាមូលដ្ឋាននៃការឃុំខ្លួនកាលពីលើកដំបូងនៅតែបន្តមាន។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះលើកឡើងតែបញ្ហាដែលបានលើកឡើងដោយសហមេធាវីការពារក្តីនៅក្នុងបណ្តឹងឧទ្ធរណ៍តែប៉ុណ្ណោះ។

<u>ហានិយភ័យនៃការគេចខ្លួន (វិធាន៦៣(៣)(ខ)(៣))</u>

២៧. អង្គបុរេជំនុំជម្រះបានសង្កេតឃើញថា តាមការពិនិត្យអំពីភាពធ្ងន់ធ្ងរនៃបទល្មើស ជនត្រូវចោទអាចនឹងទទួលការផ្តន្ទាទោសដាក់ពន្ធនាគារពីប្រាំឆ្នាំ រហូតដល់មួយជីវិត ប្រសិនបើគាត់ត្រូវបានរកឃើញថាមានកំហុស។ គ្មានភស្តុតាងថ្មីដែលដាក់នៅក្នុងសំណុំរឿង អាចនាំឱ្យមានការសន្និដ្ឋានថា កាលៈទេសៈមានការផ្លាស់ប្តូរ ចាប់តាំងពីចេញសេចក្តីសម្រេចពីមុនអំពីការឃុំខ្លួនបណ្តោះអាសន្ន។ លើសពីនេះ ភស្តុតាងថ្មីដែលបានដាក់បញ្ចូលនៅក្នុងសំណុំរឿង បានបន្ថែមនូវទឡ្ហីករណ៍គាំទ្រចំពោះការទាក់ទងគ្នារវាងអំពើដែលចោទប្រកាន់ និងជនត្រូវចោទ ហេតុដូច្នេះទឡ្ហីករណ៍នេះបានដាក់សម្ពាធបន្ថែមទៀតលើជនត្រូវចោទ[20]។

២៨. ទឡ្ហីករណ៍របស់សហមេធាវីការពារក្តីដែលបានលើកឡើងអំពីភាពចាស់ជរា និងការជាប់ឃុំឃាំងរបស់ប្រពន្ធជនត្រូវចោទថា ជាកត្តាជួយកាត់បន្ថយយ៉ាងច្រើនទាំងលទ្ធភាព និងទឹកចិត្តក្នុងការគេចខ្លួន គឺជាទឡ្ហីករណ៍មិនគួរឱ្យជឿទេ។ មិនមានភស្តុតាង ឬព័ត៌មានដែលបង្ហាញថា

[20] សូមមើលកថាខណ្ឌ២៣ ខាងលើ។

មនុស្សចាស់ជរាមិនអាចធ្វើដំណើរបាននោះទេ។ លើសពីនេះ ហានិយភ័យនៃការគេចខ្លួនរបស់ប្រពន្ធជនត្រូវចោទ ត្រូវបានបញ្ជាក់ដោយអង្គជំនុំជម្រះនេះរួចហើយ [21] ។ ករណីនេះអាចចាត់ទុកថាជាស្ថានទម្ងន់ទោស ជាជាងចាត់ទុកជាស្ថានសម្រាលទោស នៅពេលដែលពិនិត្យមើលហានិយភ័យនៃការគេចខ្លួនរបស់ជនត្រូវចោទ។

២៩. ផ្អែកលើមូលហេតុទាំងអស់ ដែលបានពិចារណានៅក្នុងសាលដីកាពីមុនរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន ដែលសាលដីកានេះនៅតែមានសុពលភាព និងដោយសារតែគ្មានការលើកឡើងនូវទទ្បីករណ៍ដែលគួរឲ្យជឿ អង្គបុរេជំនុំជម្រះយល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្ន នៅតែជាវិធានការចាំបាច់ក្នុងការធានាវត្តមានរបស់ជនត្រូវចោទនៅក្នុងអំឡុងពេលដំណើរការនីតិវិធី។

<u>ដើម្បីការពារសន្តិសុខឲ្យជនត្រូវចោទ (វិធាន៦៣(៣)(ខ)(៤))</u>

៣០. អង្គបុរេជំនុំជម្រះសង្កេតឃើញថា សហចៅក្រមស៊ើបអង្កេតបានរកឃើញនៅក្នុងដីកាសម្រេចបន្តចិរវេលាថា លក្ខខណ្ឌនៃវិធាន៦៣(៣)(ខ)(៤) ដែលចាំបាច់ក្នុងការឃុំខ្លួនជនត្រូវចោទ គឺនៅតែបំពេញ បើតាមការរកឃើញរបស់អង្គបុរេជំនុំជម្រះនៅក្នុងសាលដីការបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍នៃការឃុំខ្លួនបណ្តោះអាសន្ន។ សហមេធាវីការពារក្តីមិនបានលើកឡើងចំពោះមុខសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះអំពីទទ្បីករណ៍ណាមួយ ឬការផ្លាស់ប្តូរកាលៈទេសៈ ដែលបង្ហាញអំពីភាពផ្ទុយគ្នាទៅនឹងការរកឃើញនៅក្នុងសាលដីកាពីមុននោះទេ។ សហចៅក្រមស៊ើបអង្កេតបានរកឃើញថា ការឃុំខ្លួនគឺជាវិធានការចាំបាច់ដើម្បីធានាសន្តិសុខរបស់ជនត្រូវចោទ។ ការពិនិត្យមើលបន្ថែមលើសំណុំរឿងដោយអង្គបុរេជំនុំជម្រះ មិនបានបង្កឲ្យមានការផ្លាស់ប្តូរនូវការសន្និដ្ឋាន ផ្ទុយទៅនឹងសេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតនោះទេ។

---

[21] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចបន្តចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩, C80/5/18។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE ECCC CETC

៣១. បន្ថែមពីលើអង្គហេតុដែលបានពិនិត្យដោយអង្គបុរេជំនុំជម្រះរួចហើយ[22] អង្គហេតុថ្មី ដូចដែលបានបញ្ជាក់ដោយដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសេចក្តីសន្និដ្ឋានតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍ បានកើតឡើងថ្មីៗដែលបង្ហាញអំពីភាពតានតឹងខ្ពស់ ដែលនៅតែបន្តមានក្នុងសង្គមកម្ពុជា ដែលជាហេតុធ្វើឲ្យមានការចាំបាច់ក្នុងការឃុំខ្លួនជនត្រូវចោទ ដើម្បីការពារសន្តិសុខដល់ជនត្រូវចោទ[23]។

៣២. សហមេធាវីការពារក្តីតវ៉ាថា ការទាក់ទងគ្នារវាង [កោសលុបចោល] និង អៀង សារី គឺដោយសារតែផ្អែកលើការសន្មតជាមុនអំពីទោសកំហុសរបស់ អៀង សារី និងរហូតដល់ការគម្រាមកំហែងមានលក្ខណៈធ្ងន់ធ្ងរ លក្ខខណ្ឌនៃវិធាន៦៣(៣)(ខ)(៥) មិនអាចប្រើប្រាស់ក្នុងការធ្វើយុត្តិកម្មនៃការឃុំខ្លួនបន្តនោះទេ។

៣៣. នៅពេលអង្គបុរេជំនុំជម្រះទទួលស្គាល់ថា នៅក្នុងដំណាក់កាលនេះ ការទាក់ទងគ្នារវាងជនត្រូវចោទនិង [កោសលុបចោល] អាចមើលឃើញគ្រាន់តែជាការចោទប្រកាន់ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ការចោទប្រកាន់បែបនេះនឹងបំពេញចិត្តអ្នកអង្កេតការមិនលម្អៀងថា ជនត្រូវចោទអាចនឹងទទួលខុសត្រូវ ឬបានប្រព្រឹត្តបទល្មើសនានា។ ហេតុដូច្នេះ នៅក្នុងការពិនិត្យអំពីកាលៈទេសៈ ដែលមានចែងនៅក្នុងវិធាន ៦៣(៣)(ខ)(៥) អង្គបុរេជំនុំជម្រះក៏បានពិចារណាអំពីភស្តុតាងថ្មីនៅក្នុងករណីនេះដែរ[24]។ អង្គបុរេជំនុំជម្រះយល់ឃើញថា ក្រោយពីមានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជនត្រូវចោទធ្លាប់បានប្រព្រឹត្តបទល្មើសដែលពាក់ព័ន្ធនឹងបទល្មើសដែលចោទប្រកាន់លើ [កោសលុបចោល]

---

[22] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ប្រឆាំងនឹងដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨, C22/I/74។

[23] សេចក្តីសន្និដ្ឋានតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ២៥។

[24] សូមមើលកថាខណ្ឌ២៣ ខាងលើ។

ហានិយភ័យ ដែលថា ការខឹងចំពោះ [កោសលុបចោល] ក៏អាចជាការខឹងចំពោះជនត្រូវចោទនេះ គឺជាហានិភ័យ ដែលមិនគួរឲ្យស្រពិចស្រពិលឡើយ[25]។

៣៤. អង្គបុរេជំនុំជម្រះសង្កេតឃើញថា ការឃុំខ្លួនបណ្ដោះអាសន្ននៅតែជាវិធានការចាំបាច់ដើម្បីការពារសន្តិសុខរបស់ជនត្រូវចោទ។

<u>ដើម្បីរក្សាសណ្ដាប់ធ្នាប់សាធារណៈ (វិធាន៦៣(៣)(ខ)(៥))</u>

៣៥. អង្គបុរេជំនុំជម្រះសង្កេតឃើញថា នៅក្នុងដីកាសម្រេចបន្តឋិរវេលានៃការឃុំខ្លួន សហចៅក្រមស៊ើបអង្កេតបានរកឃើញថា លក្ខខណ្ឌនៃវិធាន ៦៣(៣)(ខ)(៥) ដែលចាំបាច់ក្នុងការឃុំខ្លួនជនត្រូវចោទ គឺនៅតែត្រូវបានបំពេញ បើតាមការរកឃើញរបស់អង្គបុរេជំនុំជម្រះនៅក្នុងសាលដីកាលើបណ្ដឹងឧទ្ធរណ៍ស្ដីពីការឃុំខ្លួនបណ្ដោះអាសន្ន។ សហមេធាវីការពារក្ដីមិនបានបង្ហាញទឡ្ហីករណ៍ណាមួយ ឬការផ្លាស់ប្ដូរកាលៈទេសៈចំពោះមុខសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ ដែលបង្ហាញនូវភាពផ្ទុយនឹងការរកឃើញលើកមុននោះទេ។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេត បានអនុវត្តនូវឆន្ទានុសិទ្ធិរបស់ខ្លួនត្រឹមត្រូវ ក្នុងផ្នែកនៃដីកាសម្រេចបន្តឋិរវេលាក្នុងការរកឃើញថា ការឃុំខ្លួនគឺជាវិធានការចាំបាច់ដើម្បីរក្សាសណ្ដាប់ធ្នាប់សាធារណៈ។

៣៦. នៅក្នុងបណ្ដឹងឧទ្ធរណ៍ សហមេធាវីការពារក្ដីបានតវ៉ាថា ការគម្រាមកំហែងដែលអាចកើតមានដោយសារការផ្លាស់ប្ដូរលក្ខខណ្ឌនៃការឃុំខ្លួនចំពោះជនអាយុ៨៣ឆ្នាំ គឺតាមការពិតមិនមាននោះទេ។ អង្គបុរេជំនុំជម្រះសង្កេតឃើញថា ដូចគ្នានឹងពេលនៃបង្ហាញការសង្ស័យសមហេតុផល ទោះបីជាជនត្រូវចោទត្រូវបានតុលាការនេះផ្ដល់នូវសច្ចធារណ៍នៃនិរទោស ប៉ុន្តែវា

---

[25] Erika Kinetz និង យន់ សាមាន "ឈុចប្រឈមមុខជាមួយចៅក្រមនៅក្នុងសវនាការជាសាធារណៈរបស់អ.វ.ត.ក ជាលើកទី១" *កាសែតThe Cambodia Daily* ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ (ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧, ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៧, C11/11, ឧបសម្ព័ន្ធA, ឯកសារភ្ជាប់A24)។

00343917



ជាការពិតដែលថា របៀបនៃការយល់ឃើញចំពោះគាត់នៅក្នុងសង្គមកម្ពុជាបានផ្លាស់ប្តូរ និងក្នុងចំណុចនេះ គាត់មិនអាចត្រូវបានគេចាត់ទុកគ្រាន់តែជា "មនុស្សចាស់អាយុ៨៣ឆ្នាំធម្មតានោះទេ"។

៣៧. អង្គបុរេជំនុំជម្រះយល់ឃើញថា អង្គហេតុដែលមានចែងនៅក្នុងសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ[26] នៅតែមាន និងអាចបង្ហាញថាការដោះលែងជនត្រូវចោទនាពេលបច្ចុប្បន្ន ពិតជាអាចរំខានដល់សណ្តាប់ធ្នាប់សាធារណៈ។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ការឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ននៅតែជាវិធានការចាំបាច់ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ។

## គ. ការយកចិត្តទុកដាក់ក្នុងការដឹកនាំការស៊ើបអង្កេត

៣៨. អង្គបុរេជំនុំជម្រះពិចារណាថា ការទាក់ទងគ្នារវាងរយៈពេលដែលជនត្រូវចោទស្ថិតនៅក្នុងមន្ទីរឃុំឃាំង និងការយកចិត្តទុកដាក់ក្នុងការដឹកនាំការស៊ើបអង្កេតគឺជាកត្តាដែលពាក់ព័ន្ធគ្នា នៅពេលពិចារណាបន្តការឃុំខ្លួន ឬការដោះលែង ដូចដែលសហមេធាវីការពារក្តីជនត្រូវចោទបានលើកឡើងដែរ។

៣៩. វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលយកមកអនុវត្តចំពោះបញ្ហាដែលពាក់ព័ន្ធនេះ មានការទាក់ទិនទៅនឹងរយៈពេលដែលត្រូវបានអនុញ្ញាតៈ វិធាន៦៣(៧) នៃវិធានផ្ទៃក្នុងចែងថា "ការពន្យារពេល [នៃការឃុំខ្លួនបណ្តោះអាសន្ន] មិនត្រូវឲ្យលើសពី ២ (ពីរ) ដងឡើយ" និងទាក់ទងទៅនឹងការយកចិត្តទុកដាក់ៈ វិធាន២១(៤) នៃវិធានផ្ទៃក្នុង ចែងថា "[ដំណើរការនីតិវិធី] នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែឈានដល់ទីបញ្ចប់នៅក្នុងអំឡុងពេលមួយដែលសមស្រប"។ "ដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ"

---

[26] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតឲ្យឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨, C22/I/74។

រួមបញ្ចូលទាំងការស៊ើបអង្កេតរបស់តុលាការផងដែរ។ ការកំណត់ចំពោះការវិវឌ្ឍនៃការស៊ើបអង្កេត គឺការចំណាយពេលវេលាមានរយៈពេល "សមស្រប" ចំណែកឯការកំណត់ចំពោះពេលវេលា ដែលជនត្រូវចោទស្ថិតក្នុងឃុំខ្លួនបណ្ដោះអាសន្ន គឺជាពេលវេលាដែលមានលក្ខណៈជាក់លាក់ណាស់។ វិធានផ្ទៃក្នុងបានបង្ហាញយ៉ាងច្បាស់អំពីរបៀបនៃការកំណត់ដូច្នេះ ពោលគឺនៅពេលឃុំខ្លួនជនត្រូវចោទ កម្រិតនៃការពិចារណាក្នុងការឃុំខ្លួនត្រូវតែខ្ពស់ ពីព្រោះសិទ្ធិមានសេរីភាពរបស់មនុស្សម្នាក់ដែលនៅតែត្រូវបានសន្មតថាគ្មានទោស នៅតែជាបញ្ហាចោទនៅឡើយ។ ហេតុដូច្នេះ ការពិចារណាថា តើអាជ្ញាធរស៊ើបអង្កេតត្រូវអនុវត្តវិធានការអ្វីខ្លះ និងថាតើវិធានការទាំងនោះ ប៉ះពាល់ដល់ស្ថានភាពរបស់ជនត្រូវចោទក្នុងកម្រិតណានោះ នៅតែជាការចាំបាច់។

៤០. បទដ្ឋានអន្តរជាតិលើកឡើងអំពីបញ្ហានេះក្នុងន័យប្រហាក់ប្រហែលគ្នា។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ICC) តម្រូវថា ការស៊ើបអង្កេត និងកិច្ចដំណើរការនីតិវិធីត្រូវតែអនុវត្តឱ្យបានឆាប់រហ័សតាមពេលដែលកំណត់ដោយច្បាប់លក្ខន្តិកៈរបស់តុលាការ។ ដរាបណាកិច្ចដំណើរការនីតិវិធីអនុលោមទៅតាមពេលវេលារបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ លក្ខខណ្ឌតម្រូវឱ្យមានការប្រព្រឹត្តិទៅដោយឆាប់រហ័ស ត្រូវបានគេចាត់ទុកថាបានបំពេញហើយ[27]។ អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងរឿងក្តី Lubanga បានកត់សម្គាល់ថា៖

> "កថាខណ្ឌ៤ នៃមាត្រា៦០ នៃច្បាប់លក្ខន្តិកៈបានប្រគល់ភារកិច្ចដល់អង្គបុរេជំនុំជម្រះឱ្យបញ្ជាក់ច្បាស់លាស់ថា ការឃុំខ្លួនជនណាម្នាក់ គឺមិនត្រូវបានពន្យារពេលសម្រាប់រយៈពេលមួយដែលមិនសមស្របនោះទេ នៅពេលដែលការពន្យារពេល ដែលមិនអាចលើកលែងឱ្យបានដោយរដ្ឋអាជ្ញា។ ការពន្យារពេលនៅក្នុងបរិបទនេះមានន័យថា ជាការខកខានមិនបាន

[27] រដ្ឋអាជ្ញា តទល់នឹង Germain Katanga និង Mathieu Ngudjolo Chui, ICC-01/04-01/07 "ការពិនិត្យ "សេចក្តីសម្រេចលើពាក្យសុំដោះលែងនៅក្នុងរយៈពេលចន្លោះមួយរបស់ Mathieu Ngudjolo Chui"" អង្គបុរេជំនុំជម្រះ I ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២00៨ ទំព័រទី១២។ សូមមើលផងដែរ រដ្ឋអាជ្ញា តទល់នឹង Thomas Lubanga Dyilo, ICC-01/04-01/06 "ការពិនិត្យឡើងវិញ "សេចក្តីសម្រេចលើពាក្យសុំដោះលែងបណ្តោះអាសន្នរបស់ Thomas Lubanga Dyilo"" អង្គបុរេជំនុំជម្រះ I ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២00៧ ទំព័រទី៦ និង៧។

អនុវត្តតាមពេលវេលាក្នុងកិច្ចដំណើរការរបស់តុលាការឆ្ពោះទៅមុខនោះទេ ដែលវាជាតម្រូវការឲ្យមានការជំនុំជម្រះដោយយុត្តិធម៌។ ប្រសិនបើការពន្យារពេលបែបនេះ ត្រូវគេជូនដំណឹងអង្គជំនុំជម្រះអាចអនុញ្ញាតឲ្យធ្វើការដោះលែងជននោះដោយមានលក្ខខណ្ឌ ឬដោយឥតលក្ខខណ្ឌ"[28]។

៤១. សេចក្តីណែនាំអាចរកបាននៅក្នុងការអនុវត្តរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប (ECHR) ដែលបានកំណត់បទដ្ឋាននៃ "ការយកចិត្តទុកដាក់យ៉ាងពិសេស" របស់អាជ្ញាធរជាតិនៅពេលធ្វើការស៊ើបអង្កេត [29] ។ នៅពេលដែលតុលាការយល់ឃើញថា មូលដ្ឋានដែលផ្តល់ដោយអាជ្ញាធរតុលាការជាតិ មានយុត្តិកម្មលើការឃុំខ្លួនបន្ត តុលាការនឹងស្រាវជ្រាវរកឲ្យឃើញថា អាជ្ញាធរជាតិបានយកចិត្តទុកដាក់ក្នុងការដឹកនាំដំណើរការនីតិវិធីរបស់ខ្លួន។

៤២. អង្គបុរេជំនុំជម្រះរកឃើញថា មានភស្តុតាងនៅក្នុងសំណុំរឿងនេះ ដែលចង្អុលបង្ហាញថា ការស៊ើបអង្កេតមានការរីកចម្រើនយ៉ាងឆាប់រហ័សសម្រាប់រយៈពេល ដែលស្ថិតក្នុងការពិចារណា។ ភស្តុតាងថ្មីត្រូវបានបញ្ជូនពីសំណុំរឿងលេខ០០១ ទៅសំណុំរឿងលេខ០០២ ដែលបន្ថែមនូវហេតុផលមានសំអាងហេតុនានា ដែលមានពីមុនដែលនាំឲ្យជឿបានថា ជនត្រូវចោទធ្លាប់បានប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[30]។ ចម្លើយរបស់សាក្សីមួយចំនួនដែលបានទទួលរួចមកហើយ និងដីកាចាត់ឲ្យស៊ើបសួរជំនួស ដែលនឹង

---

[28] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Germain Katanga និង Mathieu Ngudjolo Chui*, សំណុំរឿងលេខ ICC-01/04-01/07 OA 4 "សាលដីកានៅក្នុងអង្គជំនុំជម្រះសាលាឧទ្ធរណ៍ ដោយ Mathieu Ngudjolo Chui ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៨ ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ I លើពាក្យសុំដោះលែងបណ្តោះអាសន្ន" ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៨ កថាខណ្ឌ ១៥។

[29] ECHR, *រឿងក្តី Ilijkov តទល់នឹង Bulgaria* សំណុំរឿងលេខ ៣៣៩៧៧/៩៦ "សាលដីកា" ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០១ កថាខណ្ឌ៧៧។ សូមមើលផងដែរ *រឿងក្តីLabita តទល់នឹង Italy* សំណុំរឿងលេខ ២៦៧៧២/៩៥ "សាលដីកា" ថ្ងៃទី៦ ខែមេសា ឆ្នាំ២០០០ កថាខណ្ឌ១៥២ និង ១៥៣។ *រឿងក្តីAssenov និងអ្នកដទៃទៀត តទល់នឹង Bulgaria* សំណុំរឿងលេខ ១៦០២/៦២ "សាលដីកា" ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៦៩។ និង *រឿងក្តីWemhoff តទល់នឹង Germany* សំណុំរឿងលេខ ២១២២/៦៤ "សាលដីកា" ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៦៨។

[30] សូមមើល កថាខណ្ឌ២៣ ខាងលើ

00343920



ត្រូវចាត់ការបង្ហាញថា សកម្មភាពស៊ើបអង្កេតនៅក្នុងរយៈពេលសម្រាប់ការពិចារណានេះ បានធ្វើច្រើនរួចមកហើយ[31]។

៤៣. សហមេធាវីការពារក្តីជនត្រូវចោទអះអាងថា ការស៊ើបអង្កេតដែលស្នើសុំដោយក្រុមមេធាវីការពារក្តី មិនទាន់ត្រូវបានចាត់ការនៅឡើយនោះទេ[32]។ អង្គបុរេជំនុំជម្រះ បានពិនិត្យមើលសំណុំរឿង និងសង្កេតឃើញថា សំណើសុំលើកទីមួយឲ្យធ្វើកិច្ចស៊ើបអង្កេតរបស់សហមេធាវីការពារក្តីជនត្រូវចោទ បានដាក់នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២00៩ តែប៉ុណ្ណោះ[33]។ សំណើនេះត្រូវបានដាក់នៅក្នុងសំណុំរឿងនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២00៩[34] ដែលមានរយៈពេលតិចជាងពីរសប្តាហ៍មុនពេលបញ្ចប់ការពិចារណាលើបណ្តឹងឧទ្ធរណ៍នេះ។ ហេតុដូច្នេះ ការពិនិត្យវាយតម្លៃអំពីរបៀបដែលសហចៅក្រមស៊ើបអង្កេតចាត់ការសំណើនេះ នៅពេលបច្ចុប្បន្ននេះ ហាក់ដូចជាការវាយតម្លៃលឿនពេក។

៤៤. តាមដែលសំណើសុំកិច្ចស៊ើបអង្កេតដាក់ដោយក្រុមមេធាវីការពារក្តីផ្សេងៗទៀត ជាប់ពាក់ព័ន្ធដែលសហមេធាវីការពារក្តីយោងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួន អង្គបុរេជំនុំជម្រះបានពិនិត្យមើលឯកសារមួយចំនួននៅក្នុងសំណុំរឿងដែលបង្ហាញថា សហចៅក្រមស៊ើបអង្កេតបានឆ្លើយតបទៅនឹងសំណើ ដោយអនុលោមតាមបទប្បញ្ញត្តិនៃវិធាន២១(៤) វិធាន៥៥(៥) និង៥៥(១0) នៃវិធានផ្ទៃក្នុង[35]។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះ បដិសេធចោលការអះអាងរបស់សហមេធាវីការពារក្តី។

---

[31] ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា កថាខណ្ឌ២៣។

[32] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១០ និង១១។

[33] សំណើលើកទីមួយរបស់មេធាវីអៀង សារី ស្នើសុំកិច្ចស៊ើបអង្កេត ថ្ងៃទី២០ ខែមីនា ឆ្នាំ២00៩, D153។

[34] សូមមើលសំណុំរឿង 00២/១៩-0៩-២00៧-អវតក/ក.ស.ច.ស៖ D153/1។

[35] សូមមើលសំណុំរឿង 00២/១៩-0៩-២00៧-អវតក/ក.ស.ច.ស៖ D100/2, D100/5, D100/I, D101/1, D102/1, D105/2, D113/1, D113/2, D114/1, D122/1, D126/1, D128/1, D136/1, D140, D140/1។

៤៥. ដោយសារតែមូលហេតុទាំងអស់នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ការដឹកនាំការស៊ើបអង្កេតនៅក្នុងរឿងក្តីនេះ បំពេញលក្ខខណ្ឌនៃការខិតខំប្រឹងប្រែង ហើយសិទ្ធិមនុស្សជាសារវ័ន្តរបស់ជនត្រូវចោទ ត្រូវបានគេគោរព[36]។

៤៦. អង្គបុរេជំនុំជម្រះយល់ឃើញថែមទៀតថា ស្ថានទម្ងន់ និងចរិតលក្ខណៈនៃឧក្រិដ្ឋកម្មនានាដែលជនត្រូវចោទបានរងនូវការចោទប្រកាន់នោះ តម្រូវឲ្យធ្វើការស៊ើបអង្កេតជាទ្រង់ទ្រាយធំ ហើយបើតាមវិសាលភាព និងការរីកចម្រើននៃការស៊ើបអង្កេតនាពេលបច្ចុប្បន្ននេះ សហចៅក្រមស៊ើបអង្កេត បានប្រើឆន្ទានុសិទ្ធិរបស់ខ្លួនចេញដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នដោយសមហេតុផល។

## ឃ. សំណើសុំឲ្យដោះលែង ឬផ្លាស់ប្តូរលក្ខខណ្ឌនៃការឃុំខ្លួន ដោយអនុញ្ញាតឲ្យមានលក្ខខណ្ឌឃុំខ្លួននៅក្នុងផ្ទះ ជាជាងការឃុំខ្លួន

៤៧. សហមេធាវីការពារក្តីបានលើកឡើងថា "លក្ខខណ្ឌសមហេតុផលនៃការឃុំខ្លួននៅក្នុងផ្ទះ នឹងធានាបាននូវការការពារគោលបំណងដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង៦៣(៣)(ខ)"[37]។

៤៨. នៅក្នុងរឿងក្តីនាពេលបច្ចុប្បន្ន អង្គបុរេជំនុំជម្រះយល់ឃើញថា លក្ខខណ្ឌនៃវិធាន៦៣(៣)(ខ) នៅតែត្រូវបានបំពេញ។ គ្រាន់តែលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌផ្សេងទៀត គឺគ្រប់គ្រាន់ដើម្បីធ្វើឲ្យមានយុត្តិកម្មក្នុងការបន្តឃុំខ្លួនជនត្រូវចោទ។ លក្ខខណ្ឌដែលស្នើឡើងដោយជនត្រូវចោទ មិនសមស្របតាមភាពចាំបាច់សម្រាប់ការឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទនោះទេ។ ស្ថិតក្រោមកាលៈទេសៈទាំងនេះ សំណើរបស់សហមេធាវីការពារក្តីស្នើសុំឲ្យដោះលែងបណ្តោះអាសន្ន ឬផ្លាស់ប្តូរលក្ខខណ្ឌនៃការឃុំខ្លួន ត្រូវបានបដិសេធចោល។

---

[36] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១/A។

[37] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១/E។

00343922

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១៧)

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទៈ**

១. បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបានជាទម្រង់តាមផ្លូវច្បាប់។

២. តម្កល់ដីការបស់សហចៅក្រមស៊ើបអង្កេត។

៣. បដិសេធចោលសំណើសុំឱ្យមានការដោះលែង (ឬផ្លាស់ប្តូរលក្ខខណ្ឌនៃការឃុំខ្លួន)។

៤. បដិសេធចោលបណ្តឹងឧទ្ធរណ៍នេះ។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះត្រូវបិទផ្លូវតវ៉ា។

សាលដីកានេះ **ប្រកាសជាសាធារណៈ** ដោយអង្គបុរេជំនុំជម្រះ ចំពោះមុខជនត្រូវចោទ និងសហមេធាវីការពារក្តីរបស់គាត់។

ភ្នំពេញ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៨

**អង្គបុរេជំនុំជម្រះ** **ប្រធាន**

Rowan DOWNING **ន័យ ថុល** Katinka LAHUIS **ហួត វុទ្ធី** **ប្រាក់ គឹមសាន**

**ក្រឡាបញ្ជី**

**សរ ច័ន្ទរ៉ាត** Entela JOSIFI